សមាគមស្វែងរកប្រាជ្ញាព្រះគម្ពីរព្រះយេស៊ូវ

ស្វែងរកប្រាជ្ញា ស្គាល់ព្រះជាម្ចាស់ គោរពសេចក្ដីពិត

# មានផ្លូវតែពីរ



# ១ ព្រះដ៏សប្បុរស និងពេញដោយព្រះចេស្ដា បានបង្កើតពិភពលោកយើងនេះ។ ព្រះក៏បានបង្កើតមនុស្សមក ដើម្បីឲ្យគ្រប់គ្រងលើផែនដីរបស់ទ្រង់។ គ្រប់គ្នា និងគ្រប់អ្វីៗទាំងអស់ គឺជារបស់ព្រះជាម្ចាស់។

<u>លក្ខណៈរបស់ព្រះជាម្ចាស់</u>

ព្រះជាម្ចាស់មានបន្ទូលនៅក្នុងគម្ពីរថា ទ្រង់អស្ចារ្យហួសពីការយល់ដឹងរបស់យើង។ ទ្រង់គង់នៅតាំងពីអស់កល្បរៀងមក គឺគ្មានពេលចាប់ផ្ដើម ហើយក៏គ្មានទីបញ្ចប់ដែរ។ ទ្រង់ខ្ពង់ខ្ពស់ជាងអ្វីៗទាំងអស់ ហើយមានគ្រប់អំណាចព្រះចេស្ដា។ ទ្រង់គង់នៅដោយអំណាចព្រះចេស្ដារបស់ទ្រង់ផ្ទាល់ គឺទ្រង់មិនត្រូវការនឹងអ្វី ដើម្បីទ្រទ្រង់ព្រះជន្មទ្រង់នោះឡើយ។ ទ្រង់ជ្រាបគ្រប់ការទាំងអស់ ហើយគង់នៅគ្រប់ទីកន្លែងក្នុងពេលតែមួយ។ ព្រះជាម្ចាស់ល្អបរិសុទ្ធ និងសុចរិត ទ្រង់ស្រឡាញ់គ្រប់ទាំងការល្អ ហើយទ្រង់ត្រូវដាក់ទោសគ្រប់ទាំងការអាក្រក់។ ប៉ុន្តែ ព្រះជាម្ចាស់ជាព្រះនៃសេចក្ដីស្រឡាញ់ មេត្តាករុណា និងប្រោសប្រណី។ ព្រះជាម្ចាស់ល្អបំផុត មានព្រះចេស្ដាបំផុត និងមានព្រះប្រាជ្ញាញាណលើសអ្វីៗទាំងអស់។ ទ្រង់ជាម្ចាស់គ្រប់គ្រង និងជាមហាក្សត្រដ៏ល្អបំផុតលើជីវិតរបស់យើង។

**នៅក្នុងរូបភាពទី១ យើងឃើញមកុដដែលតំណាងឲ្យព្រះជាស្ដេច។**

ព្រះគម្ពីរបានសម្ដែងថា **«ឱព្រះអម្ចាស់ ជាព្រះនៃយើងរាល់គ្នាអើយ ទ្រង់គួរនឹងទទួលសិរីល្អ កិត្តិនាម និងព្រះចេស្ដា ដ្បិតទ្រង់បានបង្កើតរបស់សព្វសារពើមក ហើយគឺដោយបំណងព្រះហឫទ័យទ្រង់ហើយ ដែលរបស់ទាំងនោះបានកើតមក ហើយមាននៅផង។»** (វិវរណៈ ៤:១១)

<u>កិច្ចការ និងគោលបំណងរបស់ព្រះជាម្ចាស់</u>

ដំបូងព្រះជាម្ចាស់បានបង្កើតវិញ្ញាណយ៉ាងច្រើន ដែលធម្មតាមនុស្សមើលមិនឃើញឡើយ យើងហៅថា ពួកទេវតា។ ទ្រង់បានបង្កើតពួកទេវតាមក ឲ្យមានអំណាច សិរីរុងរឿង និងភាពបរិសុទ្ធ ដើម្បីឲ្យពួកគេអាចបំពេញព្រះហឫទ័យព្រះជាម្ចាស់នៅឯស្ថានដ៏ខ្ពស់បំផុត។

**នៅក្នុងរូបភាពទី១ យើងឃើញទេវតាទាំងអស់កំពុងលុតជង្គង់ថ្វាយបង្គំព្រះជាម្ចាស់។**

បន្ទាប់មក ព្រះជាម្ចាស់បានបង្កើតចក្រវាល និងរបស់សព្វបែបយ៉ាងនៅក្នុងចក្រវាល។ សូមក្រឡេកមើលជុំវិញអ្នក ធម្មជាតិទាំងអស់ដែលអ្នកបានឃើញ គឺជាស្នាព្រះហស្តរបស់ព្រះជាម្ចាស់។ ប៉ុន្តែ របស់ដែលពិសេសជាងគេបំផុត ដែលទ្រង់បានបង្កើតមក គឺមនុស្សប្រុស និងមនុស្សស្រីដំបូង ដែលមានឈ្មោះថា អ័ដាម និង អេវ៉ា។ ទ្រង់បានបង្កើតមនុស្សមកឲ្យខុសប្លែកពីសត្វ ដោយប្រទានឲ្យមនុស្សមានលក្ខណៈខ្លះដូចព្រះអង្គ ដូចជាគំនិតប្រាជ្ញា អារម្មណ៍ ភាសា និងសេចក្ដីស្រឡាញ់ជាដើម។ ព្រះធ្វើដូច្នេះ ដើម្បីឲ្យមនុស្សអាចស្គាល់និងស្រឡាញ់ទ្រង់ ស្ដាប់និងនិយាយជាមួយទ្រង់ ធ្វើតាមនិងបម្រើទ្រង់។ ដូច្នេះ ការស្គាល់ និងការស្រឡាញ់ព្រះជាម្ចាស់ គឺជាគោលដៅដ៏ធំជាងគេបំផុតសម្រាប់ជីវិតមនុស្សយើង។ ព្រះជាម្ចាស់បានប្រគល់ឲ្យមនុស្សគ្រប់គ្រង និងសោយរាជ្យលើពិភពលោកនេះ។ កិច្ចការនេះមិនពិបាកទេ ពីព្រោះកាលដើមដំបូងនោះ គ្មានអំពើបាប ជំងឺ សេចក្ដីស្លាប់ ការឈឺចាប់ ការលះលែង ការកុហក និងការសម្លាប់គ្នាឡើយ។

**នៅក្នុងរូបភាពទី១ យើងឃើញអ័ដាម និងអេវ៉ាញញឹម ដោយសារពួកគាត់កំពុងរស់នៅក្នុងពន្លឺដ៏ល្អរបស់ព្រះ ហើយមានទំនាក់ទំនងល្អឥតខ្ចោះជាមួយគ្នា និងជាមួយព្រះជាម្ចាស់។**

**ប៉ុន្តែ តើមានអ្វីបានកើតឡើង? ហេតុអ្វីបានជាពិភពលោកសព្វថ្ងៃនេះមិនដូចជាគ្រាដំបូងនោះ?**



## ២ យើងទាំងអស់គ្នាបានបដិសេធព្រះជាម្ចាស់ ដែលជាព្រះមហាក្សត្រដ៏ពិត ហើយថែមទាំងបានចូលរួមក្នុងការបះបោរប្រឆាំងនឹងទ្រង់ផងដែរ។

**ការបះបោររបស់អារក្សសាតាំង**

ជាដំបូង ទេវតាដ៏ខ្លាំងពូកែមួយ ដែលឥឡូវយើងហៅថា អារក្សសាតាំង បានបះបោរប្រឆាំងនឹងព្រះជាម្ចាស់។ ទេវតាមួយចំនួនទៀតក៏បានចូលរួមនឹងសាតាំងដែរ ទេវតាទាំងនេះបានក្លាយទៅជាវិញ្ញាណអាក្រក់ទាំងឡាយ ដែលយើងហៅថា ព្រាយបិសាច អារុក្ខអារក្ខអ្នកតានោះឯង។ ពួកវាទាំងអស់ជាសត្រូវនឹងព្រះជាម្ចាស់ ហើយប្រឆាំងនឹងផែនការល្អរបស់ទ្រង់ជានិច្ច។ តែវិញ្ញាណកុហកបោកប្រាស់ទាំងនេះ មិនអាចយកឈ្នះលើព្រះជាម្ចាស់បានឡើយ ពីព្រោះព្រះមានគ្រប់អំណាចព្រះចេស្តា។ ប៉ុន្តែ ពួកវាអាចប្រើអំណាចរបស់វា ដើម្បីព្យាយាមត្រួតត្រាលើមនុស្ស និងរបស់ផ្សេងៗ ដែលព្រះបានបង្កើត។

នៅក្នុងរូបភាពទី២ យើងឃើញអារក្សសាតាំង និងបរិវាររបស់វាដែលបានដាច់ចេញពីព្រះ។ ពួកវាស្ថិតនៅក្នុងភាពងងឹត។ បាបរបស់ពួកវាប្រៀបដូចជាជញ្ជាំងដ៏ធំ ហើយខ្ពស់ខណ្ឌរវាងពួកវា និងព្រះជាម្ចាស់។

**ការបះបោររបស់ឪពុកម្តាយដំបូង**

ព្រះគម្ពីរបានប្រាប់យើងទៀតថា អារក្សសាតាំងបានល្បួងអ័ដាម និងអេវ៉ា ដែលជាឪពុកម្តាយដំបូងរបស់យើង ឲ្យចូលរួមក្នុងការបះបោរទាស់នឹងព្រះជាម្ចាស់។ វាបានកុហកពួកគាត់ថា ការបះបោរទាស់នឹងព្រះមិននាំឲ្យមានសេចក្តីស្លាប់ និងសេចក្តីវេទនា ដូចដែលព្រះបានព្រមានមុននោះទេ តែនឹងនាំឲ្យមានចំណេះដឹងដូចជាព្រះ សុភមង្គល និងអំណាចវិញ។ ដូច្នេះ អ័ដាម និងអេវ៉ាបានសម្រេចចិត្តជឿតាមការកុហករបស់សាតាំង ដោយពួកគាត់សង្ឃឹមថា អាចធ្វើជាម្ចាស់លើខ្លួនឯង។ តែតាមពិត ពួកគាត់បានប្រគល់សិទ្ធិគ្រងរាជ្យលើផែនដីនេះដល់សាតាំង ហើយធ្លាក់ក្នុងកណ្តាប់ដៃរបស់វាវិញ។

នៅក្នុងរូបភាពទី២ យើងឃើញមកុដនៅលើឪពុកម្តាយដំបូងរបស់យើង ហើយគាត់បានដាច់ចេញពីព្រះនៅក្នុងភាពងងឹតជាមួយសាតាំង។ អ័ដាម និងអេវ៉ាមិនញញឹម ដោយសារពួកគាត់លែងមានទំនាក់ទំនងល្អឥតខ្ចោះជាមួយព្រះទៀតហើយ។

**កូនចៅរបស់អ័ដាមទាំងអស់ត្រូវបានដាច់ចេញពីព្រះជាម្ចាស់**

សូម្បីតែសព្វថ្ងៃនេះក្តី មនុស្សគ្រប់ជាតិសាសន៍ទាំងអស់មិនចង់ឲ្យព្រះជាម្ចាស់គ្រប់គ្រងលើពួកគេទេ។ យើងម្នាក់ៗក៏បានចូលរួមនឹងការបះបោររបស់សាតាំងដែរ។ យើងបដិសេធមិនចង់បានព្រះជាម្ចាស់ធ្វើជាមហាក្សត្រលើយើងទេ ហេតុដូច្នេះហើយបានជាពិភពលោកមានពេញទៅដោយសង្គ្រាម ការលែងលះ ការផិតក្បត់ ការមិនស្តាប់បង្គាប់ឪពុកម្តាយ ការថ្វាយបង្គំរូបចម្លាក់ ការប្រមឹក និងការលោភលន់ជាដើម។ អំពើបាបដ៏អាក្រក់ជាងគេរបស់យើង គឺយើងមិនព្រមគោរព និងដឹងគុណដល់ព្រះជាម្ចាស់ឡើយ សូម្បីតែយើងដឹងថា គឺទ្រង់ហើយ ដែលបានបង្កើតរបស់សព្វសារពើទាំងអស់មកក៏ដោយ។ យើងចង់បានរបស់ដែលព្រះបានបង្កើតមក ប៉ុន្តែមិនចង់បានព្រះដែលបានបង្កើតរបស់ទាំងនោះឡើយ។ អ្វីដែលកាន់តែអាក្រក់ទៅទៀតនោះ គឺយើងយករបស់ដែលព្រះជាម្ចាស់បានបង្កើតមក ទៅសែនដល់វិញ្ញាណអាក្រក់ទាំងឡាយ ដែលជាសត្រូវរបស់ព្រះទៅវិញ។ ការបដិសេធព្រះជាម្ចាស់នេះហើយ ដែលព្រះរាប់ថា «បាប»។ ឥឡូវនេះមនុស្សយើងស្ថិតនៅក្នុងភាពងងឹត ដាច់ចេញពីព្រះជាម្ចាស់ ហើយស្ថិតនៅក្រោមការត្រួតត្រារបស់អារក្សសាតាំង និងពួកបរិវាររបស់វា។

តើព្រះមានបន្ទូលដូចម្តេចចំពោះយើងដែលបានបះបោរប្រឆាំងនឹងទ្រង់? ទ្រង់មានបន្ទូលថា **«គ្មានអ្នកណាសុចរិតសោះ សូម្បីតែម្នាក់ក៏គ្មានផង គ្មានអ្នកណាដែលយល់ គ្មានអ្នកណាដែលស្វែងរកព្រះ គ្រប់គ្នាបានបែរចេញ ហើយត្រឡប់ជាឥតប្រយោជន៍ទាំងអស់គ្នា គ្មានអ្នកណាដែលប្រព្រឹត្តតាមសេចក្តីសប្បុរសសោះ តែម្នាក់ក៏គ្មានផង»** (រ៉ូម ៣:១០-១២)

**តើព្រះជាម្ចាស់បណ្តោយឲ្យការបះបោររបស់យើងនៅតែបន្តរហូតឬ?**



## ៣ ព្រះជាម្ចាស់នឹងបញ្ចប់ការបះបោរ ហើយដាក់ទោសដល់អ្នកបះបោរទាំងអស់។

**ចម្លើយរបស់ស្តេចដ៏សុចរិត**

ប្រសិនបើស្តេចមួយអង្គជ្រាបថា មានការបះបោរ ប៉ុន្តែទ្រង់អត់ចាត់ការអ្វីសោះ នោះយើងនឹងគិតថា ទ្រង់មិនស្រឡាញ់ប្រទេសជាតិ ហើយមិនគោរពអង្គទ្រង់ផ្ទាល់ឡើយ។ តែព្រះជាម្ចាស់វិញ ទ្រង់បានកាត់ទោសអារក្សសាតាំងភ្លាមនៅពេលវាបះបោរ ដោយបណ្តេញវា និងពួកអារក្សរបស់វា ចេញពីព្រះវត្តមានទ្រង់។ ព្រះជាម្ចាស់ក៏បានកាត់ទោសឪពុកម្តាយដំបូងរបស់យើងភ្លាមដែរ នៅពេលពួកគាត់ចូលរួមនឹងការបះបោររបស់សាតាំង។

**នៅក្នុងរូបភាពទី៣ យើងឃើញថា មនុស្សយើងរស់នៅក្នុងភាពងងឹត ដាច់ចេញពីព្រះជាម្ចាស់ដោយសារតែបាបរបស់ខ្លួន ហើយក៏ត្រូវស្ថិតក្រោមការត្រួតត្រាដ៏អាក្រក់របស់សាតាំងទៀតផង។ បាបរបស់យើងប្រៀបដូចជាជញ្ជាំងដ៏ធំ ហើយខ្ពស់ខណ្ឌរវាងយើង និងព្រះជាម្ចាស់។**

**លទ្ធផលនៃអំពើបាបរបស់យើង**

ការបះបោររបស់យើងទាស់នឹងព្រះជាម្ចាស់បាននាំមកនូវការឈឺចាប់ និងការអាក្រក់យ៉ាងច្រើនដល់ពិភពលោកនេះ ព្រមទាំងការមើលងាយដល់ព្រះជាម្ចាស់ទៀត។ ដោយហេតុនោះហើយបានជាទ្រង់ត្រូវតែដាក់ទោស ហើយការដាក់ទោសដែលព្រះបានសម្រេចនោះ គឺសមនឹងបាបដែលយើងបានធ្វើ។ តើសមយ៉ាងម៉េច? នៅពេលយើងបះបោរ គឺប្រៀបដូចជាយើងនិយាយទៅកាន់ព្រះជាម្ចាស់ថា «យើងមិនព្រមឲ្យទ្រង់សោយរាជ្យលើយើងទេ យើងចង់គ្រប់គ្រងជីវិតដោយខ្លួនឯង ចូរថយចេញឲ្យឆ្ងាយទៅ»។ ដូច្នេះ ព្រះប្រទានតាមការទាមទារចង់បានរបស់យើង គឺយើងដាច់ចេញពីព្រះជារៀងរហូត។ ក៏ប៉ុន្តែដោយព្រោះព្រះជាម្ចាស់ គឺជាប្រភពនៃជីវិត និងប្រភពនៃការល្អទាំងអស់ ដូច្នេះការដាច់ចេញពីព្រះជាម្ចាស់ គឺនាំឲ្យសេចក្តីស្លាប់ និងសេចក្តីវេទនាចូលមកផែនដី ដូចដែលព្រះជាម្ចាស់បានព្រមានរួចមកហើយ មិនមែននាំឲ្យមានប្រាជ្ញា ការអរសប្បាយ និងសេរីភាពដូចដែលសាតាំងបានកុហកនោះឡើយ។ ព្រះជាម្ចាស់តែងតែមានបន្ទូលពិតជានិច្ច។ អ័ដាម និងអេវ៉ាបានបាត់បង់ទំនាក់ទំនងជិតស្និទ្ធជាមួយនឹងព្រះជាម្ចាស់ភ្លាម។ ការដាច់ចេញពីព្រះនេះហើយ ជាសេចក្តីស្លាប់ពិតប្រាកដ ដែលនាំឲ្យរូបកាយរបស់មនុស្សលោកគ្រប់គ្នាត្រូវស្លាប់ដែរ។ មិនតែប៉ុណ្ណោះ ចុងក្រោយមនុស្សលោកត្រូវទទួលទោស ដាច់ចេញពីព្រះអស់កល្បជានិច្ចនៅក្នុងស្ថាននរក ។ ព្រះជាម្ចាស់បានបង្កើតស្ថាននរក ដើម្បីដាក់ទោសអស់កល្បជានិច្ចចំពោះអារក្សសាតាំង និងពួកបរិវាររបស់វា។ ប៉ុន្តែអស់អ្នកណាដែលចូលរួមនឹងការបះបោររបស់សាតាំង ក៏នឹងត្រូវទទួលទោសនៅកន្លែងនោះដែរ។ សេចក្តីសម្រេចនេះយុត្តិធម៌ណាស់។ ព្រះគម្ពីរចែងថា ព្រះជាម្ចាស់ **«បានតម្រូវឲ្យមនុស្សទាំងអស់ស្លាប់១ដង រួចសឹមជាប់សេចក្តីជំនុំជម្រះ»** (ហេព្រើរ ៩:២៧)

**នៅក្នុងរូបភាពទី៣ យើងឃើញលទ្ធផល២នៃអំពើបាបរបស់មនុស្សយើង។ យើងត្រូវតែស្លាប់ ហើយពណ៌ក្រហមនៅក្នុងរូបភាពនេះតំណាងឲ្យស្ថាននរក។**

**ដូច្នេះ តើមានសេចក្តីសង្ឃឹមសម្រាប់យើងដែលជាអ្នកបះបោរដែរឬទេ? ប្រាកដជាមាន!**

បន្ទាប់ពីអ័ដាម និងអេវ៉ាបានធ្វើបាប ព្រះជាម្ចាស់បានសន្យាជាច្រើនកន្លែងក្នុងព្រះគម្ពីរថា ថ្ងៃណាមួយ ទ្រង់នឹងចាត់អ្នកសង្គ្រោះឲ្យមក ដើម្បីបំផ្លាញអារក្សសាតាំង និងពួកបរិវាររបស់វា រំដោះមនុស្សចេញពីអំពើបាប និងសេចក្តីស្លាប់ ហើយនាំមនុស្សត្រឡប់មកឯព្រះជាម្ចាស់វិញ។



## ៤ ដោយសារព្រះជាម្ចាស់ស្រឡាញ់យើង ទ្រង់បានចាត់ព្រះរាជបុត្រាទ្រង់ឲ្យមកផែនដី ដើម្បីរំដោះយើងចេញពីបាប អារក្សសាតាំង និងសេចក្ដីស្លាប់។

**ព្រះជាម្ចាស់បានយកកំណើតជាមនុស្ស**

ព្រះជាម្ចាស់មិនបានបោះបង់ចោលយើងទៅតាមអំពើបាប និងការបះបោររបស់យើងនោះទេ។ នៅក្នុងព្រះគម្ពីរ ទ្រង់បានសន្យាម្ដងហើយម្ដងទៀតថា នឹងចាត់ស្ដេចដ៏ពិតមួយអង្គមក ដើម្បីសង្គ្រោះយើងពីអំពើបាបរបស់យើង។ កាលពីជាង២០០០ឆ្នាំមុន ព្រះជាម្ចាស់បានចាត់ព្រះរាជបុត្រារបស់ទ្រង់ដែលជាព្រះអាទិករ ឲ្យមកប្រសូតជាមនុស្សនៅប្រទេសអ៊ីស្រាអែល ដែលស្ថិតនៅទ្វីបអាស៊ីខាងលិច។ ទ្រង់មានព្រះនាមថា «ព្រះយេស៊ូវគ្រីស្ទ»។ «យេស៊ូវ» មានន័យថា «ព្រះអង្គសង្គ្រោះ»។ «គ្រីស្ទ» សំដៅទៅលើតំណែងរបស់ទ្រង់ជាស្ដេច ដែលព្រះបានសន្យានឹងចាត់មក ដើម្បីសង្គ្រោះមនុស្សលោក។ យោងតាមព្រះគម្ពីររបស់ព្រះ នេះគឺជាគោលបំណងរបស់ព្រះយេស៊ូវក្នុងការយាងមកផែនដីនេះ គឺព្រះយេស៊ូវ **«បានមក ដើម្បីនឹងរក ហើយជួយសង្គ្រោះដល់មនុស្សបាត់បង់»** (លូកា ១៩:១០)

**នៅក្នុងរូបភាពទី៤ យើងឃើញព្រួញមួយដែលប្រាប់យើងថា ព្រះជាម្ចាស់បានចាត់ព្រះយេស៊ូវឲ្យយាងចុះមកក្នុងពិភពលោកនេះ។**

**លក្ខណៈរបស់ព្រះយេស៊ូវ**

ព្រះយេស៊ូវបានចុះចូលនឹងការគ្រប់គ្រងរបស់ព្រះជាម្ចាស់ទាំងស្រុង មិនដែលបះបោរដូចជាយើងរាល់គ្នាឡើយ។ ទ្រង់ធ្វើតាមសេចក្ដីបង្គាប់ទាំងអស់របស់ព្រះជាម្ចាស់ ដែលយើងតែងតែបានរំលង ដូចជាកុំឲ្យថ្វាយបង្គំរូបចម្លាក់ឲ្យសោះ ត្រូវស្ដាប់បង្គាប់ឪពុកម្ដាយ ត្រូវស្រឡាញ់ព្រះឲ្យអស់ពីចិត្ត កុំឲ្យកុហកឲ្យសោះ កុំលួចឲ្យសោះ កុំសម្លាប់មនុស្សឲ្យសោះ កុំផិតក្បត់ឲ្យសោះ និងកុំលោភលន់ឲ្យសោះ។ ព្រះយេស៊ូវមិនដែលធ្វើបាបឡើយ សូម្បីតែបាបតូចមួយ។

**នៅក្នុងរូបភាពទី៤ យើងឃើញព្រះយេស៊ូវគង់នៅក្នុងពន្លឺនៃព្រះជាម្ចាស់គ្រប់ពេលវេលា មិនដែលរស់នៅក្នុងភាពងងឹតនៃអំពើបាបឡើយ។**

**អំណាចព្រះចេស្ដារបស់ព្រះយេស៊ូវ**

នៅពេលយើងអានអំពីឆាកជីវិតរបស់ព្រះយេស៊ូវនៅក្នុងព្រះគម្ពីរបរិសុទ្ធ យើងឃើញថា ទ្រង់មានសិទ្ធិអត់ទោសបាបដល់មនុស្ស។ ទ្រង់ក៏បានសម្ដែងព្រះចេស្ដារបស់ទ្រង់លើជំងឺ និងសេចក្ដីស្លាប់ ដោយប្រោសមនុស្សឈឺឲ្យបានជាឡើងវិញ ហើយថែមទាំងប្រោសមនុស្សស្លាប់ឲ្យបានរស់ពីស្លាប់ឡើងវិញផងដែរ។ ទ្រង់បានសម្ដែងព្រះចេស្ដារបស់ទ្រង់លើពួកអារក្ស ហើយនិងធម្មជាតិ។ ហេតុអ្វីបានជាពួកអារក្ស ធម្មជាតិ ព្រមទាំងសេចក្ដីស្លាប់ផង ត្រូវស្ដាប់បង្គាប់ទ្រង់ដូច្នេះ? ពីព្រោះព្រះយេស៊ូវ គឺជាអ្នកបង្កើតពិភពលោក ដែលបានយាងមកផែនដីនេះ ដើម្បីសង្គ្រោះយើង។ គ្រប់របស់សព្វសារពើ និងមនុស្សទាំងអស់ត្រូវតែស្ដាប់បង្គាប់ទ្រង់។

**តើព្រះយេស៊ូវអាចសង្គ្រោះយើង ដែលមានពេញដោយអំពើបាបបានយ៉ាងដូចម្ដេច?**



## ៥ ព្រះយេស៊ូវបានលោះយើង ដោយសុគតជំនួសយើង។

**<u>ផែនការរបស់មនុស្ស</u>**

នៅពេលព្រះយេស៊ូវមានព្រះជន្មប្រហែលជា៣៣ឆ្នាំ នោះទ្រង់បានបណ្ដោយឲ្យមនុស្សអាក្រក់ចាប់ទ្រង់ ហើយធ្វើគុតទ្រង់នៅលើឈើឆ្កាង។ ហេតុអ្វីបានជាព្រះយេស៊ូវដែលគ្មានបាបសោះ ត្រូវសុគត ហើយដាច់ចេញពីព្រះនៅក្នុងភាពងងឹតដូច្នេះ? គឺយើងទេដែលសមនឹងទទួលការនោះ ចុះហេតុអ្វីបានជាព្រះយេស៊ូវទទួលទៅវិញ?

**នៅក្នុងរូបភាពទី៥ យើងឃើញព្រះយេស៊ូវនៅក្នុងភាពងងឹត ហើយដាច់ចេញពីព្រះជាម្ចាស់ ដូចជាឪពុកម្ដាយដំបូងរបស់យើងនៅក្នុងរូបភាពទី២។**

**<u>ផែនការរបស់ព្រះជាម្ចាស់</u>**

ចម្លើយដ៏អស្ចារ្យគឺ ព្រះយេស៊ូវបានសុគតជំនួសយើង ដើម្បីសង្គ្រោះយើងតាមផែនការរបស់ព្រះជាម្ចាស់! នៅលើឈើឆ្កាង ព្រះយេស៊ូវសុខចិត្តលះបង់ព្រះជន្មទ្រង់ទទួលយកគ្រប់ទាំងការដាក់ទោសពីព្រះជាម្ចាស់ ដែលយើងសមនឹងទទួល ដោយសារបាបរបស់យើង។ ព្រះយេស៊ូវដ៏សុចរិតបានទទួលទោសជំនួសមនុស្សទុច្ចរិត ដូចជាយើង។ នៅលើឈើឆ្កាង ព្រះយេស៊ូវបានទទួលការដាច់ចេញពីព្រះជាម្ចាស់ជំនួសយើង ដើម្បីកុំឲ្យយើងត្រូវដាច់ចេញពីព្រះជាម្ចាស់ទៅក្នុងស្ថាននរកជារៀងរហូតនោះឡើយ។ នៅលើឈើឆ្កាង ព្រះយេស៊ូវបានយកឈ្នះលើអំពើបាប សេចក្ដីស្លាប់ និងអារក្សសាតាំង ដោយការសងថ្លៃទោសនៃអំពើបាបជំនួសយើង។ ទ្រង់បានរុះជញ្ជាំងចេញ គឺជាជញ្ជាំងនៃអំពើបាបរបស់យើង ដោយយកបាបទាំងអស់នោះមកដាក់លើអង្គទ្រង់ផ្ទាល់ ដើម្បីឲ្យយើងត្រឡប់មកឯព្រះជាម្ចាស់បាន។ ទ្រង់ធ្វើការទាំងអស់នេះដោយព្រោះតែសេចក្ដីស្រឡាញ់ដ៏ធំក្រៃលែងរបស់ទ្រង់ចំពោះយើង។

ព្រះជាម្ចាស់មានបន្ទូលយ៉ាងច្បាស់ក្នុងព្រះគម្ពីរថា **«ព្រះគ្រីស្ទទ្រង់បានរងទុក្ខម្ដង ដោយព្រោះបាបដែរ គឺជាព្រះដ៏សុចរិត ទ្រង់រងទុក្ខជំនួសមនុស្សទុច្ចរិត ដើម្បីនឹងនាំយើងរាល់គ្នាទៅដល់ព្រះ»** (១ពេត្រុស ៣:១៨)

ក្រោយពីព្រះយេស៊ូវបានសុគត ពួកអ្នកដែលស្រឡាញ់ទ្រង់បានបញ្ចុះសពទ្រង់ក្នុងផ្នូរ។

**តើដំណើររឿងបានចប់ត្រឹមនោះឬ? ប្រសិនបើព្រះយេស៊ូវ ជាស្ដេច នៅតែសុគតរហូត តើទ្រង់អាចសង្គ្រោះយើងពីទោសនៃអំពើបាបរបស់យើង និងផ្សះផ្សាយើងជាមួយនឹងព្រះជាម្ចាស់បានដែរឬទេ?**



## ៦ ព្រះយេស៊ូវបានយកជ័យជម្នះលើសេចក្ដីស្លាប់ ដោយទ្រង់រស់ពីសុគតឡើងវិញ។ ទ្រង់គឺជាមហាក្សត្រដ៏ពិតនៃពិភពលោកនេះ ហើយទ្រង់នឹងយាងមកផែនដីម្ដងទៀត ដើម្បីជំនុំជម្រះមនុស្សលោកទាំងអស់។

**ព្រះយេស៊ូវបានរស់ពីសុគតឡើងវិញ ហើយមានជ័យជម្នះលើសេចក្ដីស្លាប់**

មុនព្រះយេស៊ូវសុគត ទ្រង់បានប្រាប់ពួកសិស្សទ្រង់ជាច្រើនដងថា មនុស្សអាក្រក់នឹងធ្វើគុតទ្រង់ តែបីថ្ងៃក្រោយមក ទ្រង់នឹងរស់ពីសុគតឡើងវិញ។ ព្រះជាម្ចាស់មិនដែលកុហកឡើយ។ គឺពិតណាស់ បីថ្ងៃក្រោយមក ព្រះបានប្រោសព្រះកាយព្រះយេស៊ូវឲ្យមានព្រះជន្មរស់ឡើងវិញមែន ដើម្បីបង្ហាញថា ព្រះយេស៊ូវបានឈ្នះលើសេចក្ដីស្លាប់ និងអារក្សសាតាំង ហើយបានសងថ្លៃទោសនៃអំពើបាបរបស់យើងរួចរាល់ហើយ។

**នៅក្នុងរូបភាពទី៦ យើងឃើញព្រះយេស៊ូវមិនជាប់ចេញពីព្រះជាប់ក្នុងភាពងងឹតទៀតទេ ផ្ទុយនឹងរូបភាពទី៥។**

**ព្រះយេស៊ូវបានត្រឡប់ទៅស្ថានសួគ៌វិញ**

ក្រោយពីរស់ឡើងវិញ ព្រះយេស៊ូវបានបង្ហាញអង្គទ្រង់ដល់សាក្សីរាប់រយនាក់ ហើយបានបង្រៀនពួកសិស្សរយៈពេល៤០ថ្ងៃទៀត។ បន្ទាប់មកទ្រង់ត្រឡប់ទៅគង់នៅលើបល្ល័ង្ករបស់ទ្រង់នៅឯស្ថានដ៏ខ្ពស់បំផុត។

**នៅក្នុងរូបភាពទី៦ យើងឃើញព្រះយេស៊ូវនៅស្ថានសួគ៌មានពាក់មកុដគឺជាស្ដេច។**

**ព្រះយេស៊ូវនឹងយាងមកផែនដីនេះម្ដងទៀត ដើម្បីជំនុំជម្រះពិភពលោក**

មុនពេលទ្រង់យាងត្រឡប់មកវិញ ដំណឹងល្អអំពីការសុគត ការរស់ឡើងវិញ និងការសោយរាជ្យរបស់ព្រះយេស៊ូវត្រូវប្រកាសដល់គ្រប់ប្រទេស និងគ្រប់ភាសា។ ព្រះយេស៊ូវបានបង្គាប់ដល់មនុស្សគ្រប់ជាតិសាសន៍ឲ្យកែប្រែចិត្តពីបាបរបស់ខ្លួន ហើយជឿទុកចិត្តលើទ្រង់។ ប្រសិនបើអ្នកត្រឡប់មកចុះចូលចំពោះទ្រង់ ហើយជឿទុកចិត្តលើទ្រង់ នោះទ្រង់នឹងអត់ទោសបាបទាំងអស់របស់អ្នក ប្រទានជីវិតអស់កល្បជានិច្ចដល់អ្នក ប្រទានអ្នកឲ្យបានត្រឡប់ជាកូនរបស់ព្រះជាម្ចាស់ ហើយនឹងប្រទានឲ្យអ្នកចូលក្នុងក្រុមគ្រួសាររបស់ទ្រង់ផងដែរ។ ព្រះវិញ្ញាណបរិសុទ្ធនៃព្រះនឹងយាងមកគង់ក្នុងអ្នក ហើយនឹងមិនចាកចេញពីអ្នកឡើយ។ សាតាំង និងពួកអារក្សរបស់វានឹងមិនអាចត្រួតត្រាលើអ្នកទៀតបានឡើយ។ ហើយនៅពេលព្រះគ្រីស្ទយាងមកជំនុំជម្រះមនុស្សលោក នោះអ្នកក៏នឹងបានសង្គ្រោះរួចពីសេចក្ដីក្រោធរបស់ព្រះជាម្ចាស់ដែរ។ មនុស្សបះបោរមិនសមនឹងទទួលសេចក្ដីស្រឡាញ់ និងសេចក្ដីសង្គ្រោះបែបនេះទេ។ អ្នកគ្មានបុណ្យកុសលល្មម ដើម្បីដោះដូរយកការអត់ទោស និងជីវិតអស់កល្បនោះឡើយ។ នោះហើយជាមូលហេតុដែលព្រះជាម្ចាស់ប្រទានសេចក្ដីសង្គ្រោះជាអំណោយទទេដល់អ្នក ពីព្រោះទ្រង់ស្រឡាញ់អ្នក។ ដោយសារព្រះយេស៊ូវបានរស់ពីសុគតឡើងវិញ ព្រះគម្ពីរបានចែងថា **«ទ្រង់បានបង្កើតយើងឡើងជាថ្មី តាមសេចក្ដីមេត្តាករុណាដ៏ធំរបស់ទ្រង់ ដើម្បីឲ្យយើងរាល់គ្នាបានសេចក្ដីសង្ឃឹមដ៏រស់ ដោយសារព្រះយេស៊ូវគ្រីស្ទ ទ្រង់រស់ពីស្លាប់ឡើងវិញ»** ( ១ពេត្រុស ១:៣ )

**ដំណឹងល្អនេះនាំអ្នកមកដល់ផ្លូវបំបែកដ៏ធំក្នុងជីវិតអ្នក។**



## ៧ មានផ្លូវតែពីរ ដែលអ្នកត្រូវជ្រើសរើស ៖ ផ្លូវនៃសេចក្តីស្លាប់ ឬផ្លូវនៃជីវិត

**ផ្លូវនៃសេចក្តីស្លាប់**

អស់អ្នកដែលបដិសេធមិនព្រមទទួលយកព្រះជាម្ចាស់ឲ្យធ្វើជាស្តេចរបស់ខ្លួន ហើយនៅតែចង់គ្រប់គ្រងលើជីវិតដោយខ្លួនឯង គឺជាអ្នកដែលជ្រើសរើសផ្លូវនៃសេចក្តីស្លាប់។ ប៉ុន្តែ ផ្លូវនេះមិនត្រឹមតែនាំមកនូវសេចក្តីទុក្ខព្រួយ និងសេចក្តីវេទនាដល់ជីវិតរបស់អ្នកប៉ុណ្ណោះទេ គឺធ្វើឲ្យអ្នកស្ថិតនៅក្រោមការត្រួតត្រារបស់អារក្សសាតាំង ហើយចុងបំផុតនៃផ្លូវនេះ គឺជាសេចក្តីស្លាប់ និងការដាច់ចេញពីព្រះជាម្ចាស់អស់កល្បជានិច្ចទៅក្នុងស្ថាននរក។

នៅខាងឆ្វេងនៃរូបភាពទី៧ យើងឃើញមនុស្សនៅក្នុងភាពងងឹត ដាច់ចេញពីព្រះ ហើយពាក់មកុដខ្លួនឯង។
យើងក៏ឃើញចុងបញ្ចប់នៃផ្លូវនេះ គឺជាសេចក្តីស្លាប់ខាងវិញ្ញាណនៅក្នុងស្ថាននរក ដាច់ចេញពីព្រះជាម្ចាស់។

**ផ្លូវនៃជីវិត**

ប៉ុន្តែ ដំណឹងល្អរបស់ព្រះយេស៊ូវនាំឲ្យមានជម្រើសមួយទៀត។ បើអ្នកចុះចូលចំពោះព្រះជាម្ចាស់ ដែលជាស្តេចដ៏ពិតលើផែនដីនេះ ហើយទុកចិត្តជឿលើព្រះយេស៊ូវគ្រីស្ទ នោះព្រះជាម្ចាស់សន្យានឹងអត់ទោសគ្រប់ទាំងអំពើបាបរបស់អ្នក ទាំងបាបពីអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល ហើយនិងរំដោះអ្នកចេញពីអំណាចរបស់អារក្សសាតាំង ព្រមទាំងប្រទានអំណោយនៃជីវិតអស់កល្បជានិច្ចជាមួយនឹងព្រះជាម្ចាស់ផងដែរ។ កុំសង្ឃឹមថា អ្នកអាចសងទោសនៃអំពើបាបរបស់អ្នកដោយសារបុណ្យកុសលរបស់អ្នកនោះឡើយ។ មនុស្សមានបាបប្រៀបដូចជាអ្នកកំពុងលង់ទឹក ដែលមិនអាចសង្គ្រោះខ្លួនឯងបានទេ គឺត្រូវការអ្នកសង្គ្រោះ។ មានតែព្រះយេស៊ូវមួយអង្គគត់ដែលសន្យាថា នឹងសង្គ្រោះអ្នកចេញពីបាប សេចក្តីស្លាប់ អារក្ស និងស្ថាននរក។ ចូរកែប្រែចិត្តពីអំពើបាប និងការបះបោររបស់អ្នក ហើយត្រឡប់មកជឿលើព្រះយេស៊ូវគ្រីស្ទវិញ នោះទ្រង់នឹងសង្គ្រោះអ្នក។

នៅខាងស្តាំនៃរូបភាពទី៧ យើងឃើញមនុស្សកំពុងលុតជង្គង់ចំពោះព្រះយេស៊ូវដោយបន្ទាបខ្លួន
រស់នៅក្នុងពន្លឺនៃព្រះ ហើយព្រះយេស៊ូវពាក់មកុដ។

ព្រះជាម្ចាស់មានបន្ទូលយ៉ាងច្បាស់លាស់ក្នុងព្រះគម្ពីរថា «ឯអ្នកណាដែលជឿដល់ព្រះរាជបុត្រា នោះមានជីវិតដ៏នៅអស់កល្បជានិច្ចហើយ តែអ្នកណាដែលមិនព្រមជឿដល់ព្រះរាជបុត្រាវិញ នោះនឹងមិនឃើញជីវិតសោះឡើយ គឺសេចក្តីក្រោធរបស់ព្រះតែងនៅជាប់លើអ្នកនោះឯង» ( យ៉ូហាន ៣:៣៦ )

**តើអ្នកអាចផ្សះផ្សានឹងព្រះជាម្ចាស់ឥឡូវនេះបានដោយរបៀបណា ?**

# មានផ្លូវតែពីរ



# សេចក្ដីអញ្ជើញឲ្យជ្រើសរើសផ្លូវនៃជីវិត

**ចូរប្រែចិត្តពីអំពើបាបរបស់អ្នក ហើយទុកចិត្តជឿលើព្រះយេស៊ូវចុះ។**



**តើពាក្យ «ការប្រែចិត្តពីអំពើបាបរបស់អ្នក» មានន័យយ៉ាងដូចម្ដេច?**

១ មានន័យថា អ្នកឈប់បះបោរប្រឆាំងនឹងព្រះជាម្ចាស់ ដោយចុះចូលនឹងទ្រង់ ដែលជាព្រះមហាក្សត្រ និងព្រះអម្ចាស់របស់អ្នកវិញ។

២ មានន័យថា អ្នកទទួលស្គាល់ថា អ្នកគ្មានគុណសម្បត្តិអ្វី ដែលអ្នកអាចថ្វាយដល់ព្រះជាម្ចាស់ ដើម្បីឲ្យទ្រង់ទទួលយកអ្នកនោះឡើយ។

៣ មានន័យថា អ្នកទទួលស្គាល់ថា អំពើបាបក្នុងខ្លួនរបស់អ្នកអាក្រក់ណាស់ ដែលពិតជានឹងបំផ្លាញអ្នក ហើយបំបែកអ្នកចេញពីព្រះទៅក្នុងស្ថាននរកអស់កល្បជានិច្ច។

**តើពាក្យ «ការទុកចិត្តជឿលើព្រះយេស៊ូវ» មានន័យយ៉ាងដូចម្ដេច?**

១ មានន័យថា អ្នកជឿថា ព្រះយេស៊ូវជាព្រះមហាក្សត្រ គឺជាព្រះអម្ចាស់នៃពិភពលោកទាំងមូល។

២ មានន័យថា អ្នកជឿថា ព្រះយេស៊ូវបានសងថ្លៃអំពើបាបគ្រប់យ៉ាងរបស់អ្នកនៅលើឈើឆ្កាង ហើយទ្រង់ក៏បានរស់ពីសុគតឡើងវិញ ដើម្បីផ្សះផ្សាអ្នកជាមួយនឹងព្រះជាម្ចាស់ផងដែរ។

៣ មានន័យថា អ្នកជឿថា ព្រះយេស៊ូវជាផ្លូវតែមួយគត់ ដែលអាចសង្គ្រោះអ្នកឲ្យរួចពីបាបបាន។



**បើអ្នកប្រែចិត្ត ហើយទុកចិត្តជឿលើព្រះយេស៊ូវ តើអ្វីទៅជាជំហានបន្ទាប់?**

១ អ្នកនឹងសម្ដែងជំនឿថ្មីដោយទទួលពិធីជ្រមុជទឹកនៅមុខក្រុមជំនុំតាមបទបញ្ជារបស់ព្រះយេស៊ូវ។

២ អ្នកនឹងថ្វាយបង្គំព្រះជាម្ចាស់ជាមួយនឹងអ្នកជឿឯទៀតៗ ហើយនឹងប្រុងក្លាយជាសមាជិកនៃក្រុមជំនុំមួយ ដែលជាគ្រួសារថ្មីរបស់អ្នក។

៣ អ្នកនឹងចំណាយពេលជាមួយព្រះជារៀងរាល់ថ្ងៃ តាមរយៈការអាននិងការពិចារណាលើព្រះបន្ទូលរបស់ព្រះ ហើយនឹងការអធិស្ឋាន។

៤ អ្នកនឹងចាប់ផ្ដើមស្ដាប់បង្គាប់ព្រះយេស៊ូវ ជាស្ដេចថ្មីរបស់ខ្លួន ដោយគោរពតាមគ្រប់ទាំងព្រះបន្ទូលនៃព្រះនៅក្នុងព្រះគម្ពីរ ជាពិសេសបទបញ្ជាសំខាន់បំផុតពីរគឺ «ត្រូវឲ្យស្រឡាញ់ព្រះអម្ចាស់ ជាព្រះនៃឯងឲ្យអស់អំពីចិត្ត» និង «ត្រូវឲ្យស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង»។ (ម៉ាថាយ ២២:៣៧-៣៩)

# ការពន្យល់សម្រាប់អ្នកប្រកាសដំណឹងល្អ

**ហេតុផលដែលយើងបានបង្កើតរូបភាពដំណឹងល្អ «មានផ្លូវតែពីរ» ឡើង ៖**

១ ដើម្បីជួយអ្នកប្រកាសដំណឹងល្អចងចាំចំណុចដែលសំខាន់បំផុត កាលណាគាត់ប្រកាសដំណឹងល្អ។

២ ដើម្បីជួយអ្នកដែលមិនសូវចេះអានអក្សរ ជាជំនួយដល់ទាំងអ្នកប្រកាស និងអ្នកស្តាប់ដំណឹងល្អ។

៣ ដើម្បីជួយអ្នកដឹកនាំក្រុមជំនុំ ក្នុងការបង្ហាត់បង្រៀនសមាជិក ឲ្យចេះផ្សាយដំណឹងល្អ។

៤ ដើម្បីជួយអ្នកប្រកាស និងអ្នកស្តាប់ចងចាំខគម្ពីរសំខាន់ ៧ខ ដែលទាក់ទងនឹងដំណឹងល្អ។

**សេចក្តីណែនាំសម្រាប់អ្នកប្រកាសដំណឹងល្អដែលប្រើប្រាស់រូបភាពដំណឹងល្អ «មានផ្លូវតែពីរ» ៖**

១ មុនអ្នកចេញទៅ អ្នកគួរតែអធិស្ឋានដល់ព្រះជាម្ចាស់ទូលសូមឲ្យទ្រង់បើកចំហចិត្តរបស់អ្នកស្តាប់ ព្រមទាំងជួយប្រទានពាក្យសម្តី ឲ្យអ្នកបើកមាត់ដោយចិត្តក្លាហាន ដែលប្រកបដោយព្រះគុណ (កូឡុស ៤:២-៥) ដើម្បីប្រកាសដំណឹងល្អទៅកាន់អ្នកនៅក្នុងសហគមន៍របស់អ្នក ដែលមិនទាន់បានឮដំណឹងល្អ ហើយមិនទាន់ស្គាល់ព្រះយេស៊ូវ។

២ អ្នកគួរតែពន្យល់រូបភាពមួយម្តង់ៗតាមលំដាប់លំដោយ កុំរំលងរូបភាពណាមួយឡើយ។ ដូចជាផ្ទះដ៏រឹងមាំត្រូវការគ្រឹះដ៏រឹងមាំជាយ៉ាងណា នោះអ្នកដែលមិនទាន់ជឿត្រូវយល់ដឹងពីមូលដ្ឋានគ្រឹះនៃដំណឹងល្អជាយ៉ាងនោះដែរ។ អ្នកដែលមិនទាន់ស្គាល់ព្រះយេស៊ូវត្រូវតែយល់ពីដំណឹងអាក្រក់មុននឹងពួកគេអាចយល់ពីសារៈសំខាន់នៃដំណឹងល្អបាន។

៣ អ្នកអាចប្រាប់ពីទីបន្ទាល់ផ្ទាល់ខ្លួនរបស់អ្នក ហើយឆ្លើយសំណួរផ្សេងៗរបស់អ្នកស្តាប់បាន ប៉ុន្តែអ្នកមិនត្រូវចាកចេញឆ្ងាយពីប្រធានបទឡើយ អ្នកគួរតែត្រឡប់មកពន្យល់រូបភាពនិមួយៗរហូតដល់ចប់។

៤ អ្នកគួរតែប្រើប្រយោគពណ៌មាស ជាសេចក្តីពន្យល់ពីទិដ្ឋភាពផ្សេងៗនៃរូបភាព ហើយខគម្ពីរពណ៌ខៀវ សម្រាប់អ្នកប្រើជាខគម្ពីរចងចាំក្នុងក្លឹបកុមារ ពេលបង្រៀនយុវជន ឬមនុស្សចាស់ៗផងដែរ។ នៅខាងក្រោមមានខគម្ពីរសំខាន់ៗផ្សេងទៀតដែលអ្នកអាចប្រើពេលអ្នកប្រកាសដំណឹងល្អ។ គឺសំខាន់បំផុតដែលអ្នកស្តាប់ដឹងថា សេចក្តីពិតទាំងអស់ដែលអ្នកកំពុងប្រកាស គឺសុទ្ធតែមកពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ មិនមែនជាគំនិតរបស់មនុស្សទេ។

| រូបភាពទី | ខគម្ពីរចងចាំ | ខគម្ពីរសំខាន់ៗបន្ថែម ដើម្បីចែកចាយ ឬទន្ទេញចាំ |
|---|---|---|
| ១ | វិវរណៈ ៤:១១ | លោកុប្បត្តិ ១:១; អេសាយ ៤៣:៧; អេសាយ ៤៥:២២; ១កូរិនថូស ៨:៦; ១យ៉ូហាន ១:៥ |
| ២ | រ៉ូម ៣:១០-១២ | យេរេមា ៣:២៥ក; ដានីយ៉ែល ៩:៨-៩; រ៉ូម ១:២១-២៣; រ៉ូម ៣:២៣; រ៉ូម ៥:១២ |
| ៣ | ហេព្រើរ ៩:២៧ | អេសាយ ៥៩:២; ម៉ាថាយ ២៥:៤៦; រ៉ូម ៦:២៣ក; ២ថែស្សាឡូនីច ១:៩; វិវរណៈ ២១:៨ |
| ៤ | លូកា ១៩:១០ | ម៉ាថាយ ១:២១; យ៉ូហាន ១៤:៦; រ៉ូម ៥:៨; ១ធីម៉ូថេ ២:៥; ១យ៉ូហាន ៣:៥ |
| ៥ | ១ពេត្រុស ៣:១៨ | អេសាយ ៥៣:៤-៦; រ៉ូម ៥:៦-៨; ២កូរិនថូស ៥:២១; កូឡុស ១:២១-២២; ១ពេត្រុស ២:២៤ |
| ៦ | ១ពេត្រុស ១:៣ | កិច្ចការ ៥:៣០-៣១; រ៉ូម ១:៤; ហេព្រើរ ៩:២៨; ១ពេត្រុស ៣:២២; វិវរណៈ ១:១៨ |
| ៧ | យ៉ូហាន ៣:៣៦ | អេសាយ ៥៥:៧; ម៉ាថាយ ៧:១៣-១៤; យ៉ូហាន ៥:២៤; កិច្ចការ ២៦:១៨; រ៉ូម ១០:៩-១១ |

៥ ចូរចាំថា អ្នកត្រូវតែទូលសូមប្រាជ្ញា និងព្រះគុណពីព្រះជាម្ចាស់ នៅពេលណាដែលអ្នកប្រកាសដំណឹងល្អ។ សូមឲ្យព្រះវិញ្ញាណបរិសុទ្ធបើកចិត្តរបស់អ្នកមិនជឿ ហើយបើកសម្តែងឲ្យគេឃើញពីអំពើបាបនៅក្នុងចិត្តរបស់គេ តាមរយៈព្រះបន្ទូលរបស់ព្រះដែលអ្នកប្រកាស។ យើងរាល់គ្នាត្រូវតែពឹងផ្អែកទាំងស្រុងលើព្រះបន្ទូលរបស់ទ្រង់ និងលើព្រះវិញ្ញាណបរិសុទ្ធ ដើម្បីឲ្យគេប្រែចិត្ត ហើយជឿលើព្រះអង្គអស់ពីចិត្ត។

ខគម្ពីរដកស្រង់ចេញពី ពគប ១៩៥៤ សមាគមព្រះគម្ពីរកម្ពុជា
កែសម្រួលដោយមានការអនុញ្ញាតពី J.D. Crowley និងង៉ែត សារិទ្ធ
© រក្សាសិទ្ធិ ២០២៥

បើអ្នកចាប់អារម្មណ៍មើលវីដេអូផ្សេងទៀត អ្នកអាចស្កេនកូដ QR នេះបាន

បើអ្នកចាប់អារម្មណ៍មើលរូបភាពដំណឹងល្អ «មានផ្លូវតែពីរ» នៅលើទូរស័ព្ទដៃ អ្នកអាចស្កេនកូដ QR នេះបាន